គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION OF THE KINGDOM OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
លេខ ៤២៧ /គម/២១

ថ្ងៃ ៣ រោច ៤ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ **ឯកឧត្តម លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីនិងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី **"កិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់"** ក្នុងគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងផ្តល់សេវាការពារក្តីតាមផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងបណ្តុះបណ្តាលចំណេះដឹងលើវិស័យច្បាប់ដល់មន្ត្រីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីនិងមន្ទីរកិច្ចការនារីរាជធានី ខេត្ត។ អនុស្សរណៈនៃការយោគយល់នេះ មានរយៈពេល ៣(បី)ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០២១ ដល់ខែធ្នូ ឆ្នាំ២០២៣។

ក្នុងអនុស្សរណៈនេះ គណៈមេធាវីមានកាតព្វកិច្ចផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ រងគ្រោះក្នុងករណីរំលោភបំពានផ្លូវភេទ រងគ្រោះក្នុងករណីធ្វើអាជីវកម្មផ្លូវភេទ និងរងគ្រោះក្នុងករណីពិសេសពាក់ព័ន្ធការបំពានសិទ្ធិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី ឬផ្តល់មេធាវីតំណាងដោយអាណត្តិដល់ស្ត្រីដែលលែងលះបណ្តាលមកពីអំពើហិង្សា។ លើសពីនេះ គណៈមេធាវីអាចចូលរួមបណ្តុះបណ្តាលចំណេះដឹងលើវិស័យច្បាប់ដល់មន្ត្រីអនុវត្តច្បាប់របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីរបស់ក្រសួងកិច្ចការនារី និងរបស់មន្ទីរកិច្ចការនារីរាជធានី ខេត្ត។ ដោយឡែកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានកាតព្វកិច្ចផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុចំនួន១ ២០០ ០០០(មួយលានពីរសែន) រៀលក្នុងមួយសំណុំរឿងដល់មេធាវីដែលបានការពារក្តីឬតំណាងដោយអាណត្តិឱ្យជនរងគ្រោះ។

គួរបញ្ជាក់ផងដែរថា គណៈមេធាវីបានចេញគោលនយោបាយលេខ០៩៨/សសគម/២១ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការពិគ្រោះយោបល់ និងការការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ។ ដូច្នេះអនុស្សរណៈនៃការយោគយល់នេះ គឺជាធាតុសំខាន់មួយនៃគោលនយោបាយខាងលើ។

គណៈមេធាវីបន្តខិតខំពង្រីកការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ជាពិសេសស្ត្រី កុមារ និងកម្មករ-និយោជិត ក្នុងគោលដៅពង្រឹងសមធម៌និងយុត្តិធម៌សង្គម និងលើកស្ទួយឧត្តមភាពនិងកិត្យានុភាពនៃវិជ្ជាជីវៈមេធាវី។

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

ប្រធានគណៈមេធាវី
មេធាវី លី ច័ន្ទតុលា
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី កុយ នាម
២-មេធាវី ទេព បុផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ងួនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទៈ
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុម ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុតា
១៩-មេធាវី ណុប គុណវឌ្ឍុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ទួន ផានិត
៣៣-មេធាវី យុត កែវសុគ្គា